**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**


- អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២១ រំពឹងថា នឹងអាចងើបឡើងមកវិញក្នុងរង្វង់ ២,៥%
- ធនាគារជាតិបន្តដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិក
- ប្រទេសកម្ពុជា អាចនឹងចាប់ផ្តើមទទួលភ្ញៀវទេសចរ ដែលជាជនជាតិចិនឱ្យមកកម្សាន្តមុនគេ
- វិស័យកាត់ដេរសម្លៀកបំពាក់ចាប់ផ្តើមមានស្ថិរភាពឡើងវិញហើយ តើមកពីកត្តាអ្វីខ្លះ?
- រដ្ឋមន្ត្រីពាណិជ្ជកម្មគ្រោងទៅប្រទេសកូរ៉េ ដើម្បីចុះហត្ថលេខា CKFTA
- រដ្ឋមន្ត្រីក្រសួងសាធារណៈការ ជំរុញការដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីបង្កើនការនាំចេញកសិផល
- ក្រសួងពាណិជ្ជកម្មត្រៀមចាត់ការ អាជីវកម្មតាមប្រព័ន្ធអនឡាញ ដែលគ្មានអាជ្ញាបណ្ណ
- CDC អនុម័តគម្រោងរោងចក្រដំឡើងរថយន្តថ្មីមួយទៀត តម្លៃ៧លានដុល្លារនៅប៉ោយប៉ែត
- ចំណូលថវិកាជាតិរបស់ប្រទេសថៃក្នុងរយៈពេល៧ខែដើមឆ្នាំ២០២១
- តម្រូវការក្នុងស្រុកកូរ៉េខាងត្បូងនៅមិនច្បាស់លាស់ បើទោះជាមានសញ្ញាណនៃការងើបឡើងវិញនៃសេដ្ឋកិច្ច
- ការវិនិយោគបរទេសនៅវៀតណាមត្រូវបានរំពឹងថានឹងកើនឡើង ទោះជាមានបញ្ហាកូវីដ១៩
- ផ្លែស្រកានាគវៀតណាម កំពុងរងទុក្ខជាថ្មីទៀត ក្រោយចិនហាមឃាត់ការនាំចូល
- ទីផ្សារភាគហ៊ុនសកលធ្លាក់ចុះដុំវិញវិបត្តិក្រុមហ៊ុនអចលនទ្រព្យចិន (EvergrandeGroup) និងថ្លៃហ្គាសអឺរ៉ុបឡើង
- ទីផ្សារតម្លៃឧស្ម័ន (ហ្គាស) ក្នុងអឺរ៉ុប បានហក់ឡើងខ្ពស់ ក្នុងអត្រាកំណើន ២៥០%



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២១ លេខ ៖ ៨៦

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២១ រំពឹងថា នឹងអាចងើបឡើងមកវិញក្នុងរង្វង់ ២,៥%



*ប្រភព ៖ AKP*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានថ្លែងថា អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងអាចងើបឡើងវិញស្ថិតនៅក្នុងរង្វង់ ២,៥% បន្ទាប់ពីធ្លាក់ចុះក្នុងកម្រិត (-១,៩%)ក្នុងឆ្នាំ២០២០។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការតម្រង់ទិសដៅគោលនយោបាយ និងធនធានរបស់ខ្លួនដើម្បីបន្តប្រយុទ្ធប្រឆាំងនឹងវិបត្តិកូវីដ-១៩ តាមរយៈការជំរុញយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាជនឱ្យបាន ១៣ លាននាក់ តាមការគ្រោងទុក ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការជួយរក្សាលំនឹងអាជីវកម្ម-ធុរកិច្ច ការស្តារនិងជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចឱ្យបានឆាប់ ដោយបង្កើនការយកចិត្តទុកដាក់លើប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ចឡើងវិញឆ្នាំ២០២១-២០២៣ ដោយផ្តោតអាទិភាពចម្បងចំនួនបីចំនុច។ ចំនុចទី១គឺ-កសាងមូលដ្ឋានសេដ្ឋកិច្ចឱ្យរឹងមាំ ដោយផ្តោតលើការធានាសុវត្ថិភាព ការគ្រប់គ្រងផលប៉ះពាល់ ការរក្សាលំនឹង និងការជំរុញឱ្យងើបឡើងវិញនៃធុរកិច្ច ដែលមានសក្តានុពលជាពិសេសក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស។ ចំនុចទី២គឺ-បន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន៖ ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម ការវិនិយោគ និងធុរកិច្ច និងការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងឯកជន។ ចំនុចទី៣គឺ- កសាងភាពធន់គឺពង្រឹងការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងជំងឺ ឬស្ថានភាពស្រដៀងគ្នា ដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមដែលរឹងមាំ មានប្រសិទ្ធភាព និងការធានាចីរភាព និងបរិយាប័ន្ននៃការស្តារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ AKP ចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១។*

## ធនាគារជាតិបន្តដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិក



*ប្រភព ៖ ខេមបូណ្ឌមីស*

នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តបញ្ចេញប្រាក់ដុល្លារអាមេរិក។ នៅក្នុងខែកញ្ញានេះ ធនាគារជាតិត្រៀមបញ្ចេញប្រាក់ដុល្លារអាមេរិក ១០០ លានដុល្លារ សម្រាប់ដាក់ឱ្យមានការដេញថ្លៃ។ ដាក់ស្តែងនៅថ្ងៃទី ២៣ ខែកញ្ញា ប្រាក់ដុល្លារចំនួន ៤០លាន បន្ថែមទៀត នឹងត្រូវបានដាក់ដេញថ្លៃ។

ការដាក់ដេញថ្លៃប្រាក់ដុល្លាររបស់ធនាគារជាតិនេះ ជាមធ្យោបាយដ៏សំខាន់ក្នុងការរក្សាតម្លៃប្រាក់រៀល និងបង្កើនទំនុកចិត្តដល់អ្នកធុរៈជន និងវិនិយោគិនលើរូបិយវត្ថុជាតិ។ លើសពីនេះ វាជាយន្តការដ៏មានសារៈសំខាន់ដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុងវិបត្តិកូវីដ-១៩ នេះ។

ការដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិក គឺជាប្រតិបត្តិការទូទៅរបស់ធនាគារកណ្តាល ដើម្បីឆ្លើយតបនឹងការប្រែប្រួលតម្រូវការ និងការផ្គត់ផ្គង់រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលនៅលើទីផ្សារប្តូរប្រាក់។ នេះជាការធ្វើអន្តរាគមន៍ ដែលត្រូវបានប្រើប្រាស់ ដើម្បីរក្សាអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាព ឬរក្សាតម្លៃប្រាក់រៀលដែលរួមចំណែកដោយផ្ទាល់ក្នុងការការពារអំណាចទិញរបស់ប្រាក់រៀល ដែលជាចំណូលរបស់ជនទូទៅ ជាពិសេសប្រជាកសិករ និងប្រជាជន ដែលមានចំណូលទាប។

នៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ធនាគារជាតិនៃកម្ពុជា បានរក្សាស្ថិរភាពតម្លៃប្រាក់រៀលបានយ៉ាងល្អប្រសើរ។ ជាលទ្ធផល ស្ថិរភាពប្រាក់រៀលបានជួយរក្សាអំណាចទិញរបស់ប្រាក់រៀល ពង្រឹងជំនឿទុកចិត្ត ព្រមទាំងលើកទឹកចិត្តសាធារណជនឱ្យប្រើប្រាស់ និងសន្សំជាប្រាក់រៀល ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។

ប្រធានសមាគមធនាគារនៅកម្ពុជា បានគាំទ្រយ៉ាងពេញទំហឹងចំពោះវិធានការដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិក ដើម្បីប្រមូលប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា។ នេះជាវិធានការដ៏មានសារសំខាន់ក្នុងការរក្សាតុល្យភាពតម្លៃប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។ លើសពីនេះ វានឹងធ្វើឲ្យប្រាក់រៀលកាន់តែមានតម្លៃ ដែលអាចរក្សាស្ថិរភាពសេដ្ឋកិច្ច និងធ្វើឱ្យអ្នករកស៊ីមានទំនុកចិត្តកាន់តែខ្ពស់លើរូបិយវត្ថុកម្ពុជា។
ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាយល់ឃើញថា ការដាក់ចេញវិធានរបស់ធនាគារជាតិនេះ វានឹងធ្វើឱ្យតម្លៃប្រាក់រៀលដែលកំពុងមានទីផ្សារល្អ កាន់តែល្អប្រសើរមួយកម្រិតទៀត។ បច្ចុប្បន្នអត្រាប្តូរប្រាក់ ១ដុល្លារអាមេរិកមានតម្លៃក្នុងរង្វង់៤ ១០០រៀល។
ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការប្រមូលប្រាក់រៀល តាមរយៈការបញ្ចេញប្រាក់ដុល្លារអាមេរិកដាក់ឱ្យគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ដែលមានលិខិតអនុញ្ញាតត្រឹមត្រូវ ដេញថ្លៃជាបន្តបន្ទាប់៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២១។*

## ប្រទេសកម្ពុជា អាចនឹងចាប់ផ្តើមទទួលភ្ញៀវទេសចរដែលជាជនជាតិចិន មកកម្សាន្តមុនគេ



*ប្រភព៖ postkhmer, 2021. រូបភាព៖ ហេង ជីវ័ន*

ប្រទេសកម្ពុជាបានត្រៀមខ្លួនរួចហើយក្នុងការទទួលភ្ញៀវទេសចរជនជាតិចិនឡើងវិញ បន្ទាប់ពីសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មានប្រសាសន៍លើកឡើងថា កម្ពុជាអាចនឹងបើកទ្វារឡើងវិញក្នុងពេលឆាប់ៗ ដើម្បីទទួលភ្ញៀវទេសចរអន្តរជាតិដែលបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ រួចរាល់ដោយផ្តើមចេញ ពីភ្ញៀវជនជាតិចិនមុនគេ។

បន្ទាប់ពីសម្រេចបានលទ្ធផលល្អជាបន្តបន្ទាប់នៃយុទ្ធនាការចាក់វ៉ាក់សាំងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ កម្ពុជាបាននិងកំពុងចាប់ផ្តើមបើកដំណើរការវិស័យសំខាន់ៗឡើងវិញជាបណ្តើរៗ ដោយផ្តើមដំបូងពីវិស័យអប់រំ ហើយបន្ទាប់មកគឺវិស័យសេវាកម្ម(ទេសចរណ៍)។

ការបើកទទួលភ្ញៀវទេសចរណ៍ដំបូងគឺអាចធ្វើជាមួយប្រទេសដែលមិនសូវមានការឆ្លងរាលដាលជំងឺកូវីដ-១៩ ខ្លាំង និងមានអត្រាចាក់វ៉ាក់សាំងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានច្រើន។ ក្នុងនោះប្រទេសចិនមានអត្រាទាបខ្លាំងបំផុត នៃការឆ្លងរាលដាលជំងឺកូវីដ-១៩នាពេលថ្មីៗ ដែលកម្ពុជាអាចបើកទទួលភ្ញៀវទេសចរណ៍ចិនមកកម្សាននៅកម្ពុជាមុនគេ។

ភ្ញៀវទេសចរអន្តរជាតិដែលចាក់វ៉ាក់សាំងហើយ ត្រូវធ្វើចត្តាឡីស័កចំនួន៧ថ្ងៃ ប៉ុន្តែពួកគេមានសិទ្ធិ (ភ្ញៀវទេសចរ) ដើរនៅក្នុងទីក្រុងដែលពួកគេធ្វើចត្តាឡីស័កនោះ គឺមិនមែនធ្វើចត្តាឡីស័កក្នុងបន្ទប់នោះទេ ហើយបន្ទាប់ពីផុត ៧ ថ្ងៃនៃថ្ងៃធ្វើចត្តាឡីស័ក គឺគេអាចចេញធ្វើដំណើរទៅតាមខេត្តដទៃទៀតបាន។

ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ភាសាចិន លោក ទៀ គីឡេង បានបញ្ជាក់ផងដែរថា សមាជិកក្នុងសមាគមបានត្រៀមខ្លួនរួចហើយក្នុងការចាប់ផ្តើមទទួលភ្ញៀវទេសចរអន្តរជាតិ ពិសេសជនជាតិចិនឡើងវិញ ដោយពេលនេះស្ទើរតែ ១០០%នៃសមាជិករបស់ខ្លួនចំនួន ៨២៧នាក់បានទទួលវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩រួចរាល់។

ទន្ទឹមនេះ ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍ កម្ពុជា បានលើកឡើងថា៖ វិស័យឯកជនពិតជាចង់ឱ្យរដ្ឋាភិបាលបើកទទួលភ្ញៀវទេសចរបរទេសដែលបានចាក់វ៉ាក់សាំងរួចរាល់ឱ្យបានឆាប់ ព្រោះបើនៅអូសបន្លាយយូរ អាចធ្វើឱ្យប្រទេសជិតខាងមានឱកាសស្រូបទាញយកភ្ញៀវទេសចរដែលមានបំណងមកកម្សាន្តនៅកម្ពុជា ឱ្យធ្វើដំណើរទៅកាន់ប្រទេសទាំងនោះវិញ។

ក្រសួងទេសចរណ៍ធ្លាប់លើកឡើងថា កម្ពុជាមានផែនការនឹងបើកទទួលភ្ញៀវទេសចរអន្តរជាតិចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ គ្រប់ដូសចាប់ពីត្រីមាសទី ៤ ឆ្នាំ ២០២១ នេះតទៅ។

របាយការណ៍ក្រសួងទេសចរណ៍ឱ្យដឹងថា ក្នុងឆ្នាំ ២០២០ កម្ពុជាទទួលបានចំណូលពីទេសចរណ៍អន្តរជាតិប្រមាណ ១,០២ប៊ីលានដុល្លារ ធ្លាក់ចុះ ៧៩,២%បើធៀបនឹងឆ្នាំ ២០១៩ ដែលមានចំនួន ៤,៩ប៊ីលានដុល្លារ។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីវិបត្តិការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩៕ *ដោយ សេន ចន្ធូ*

*ប្រភព៖ postkhmer.ចេញផ្សាយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១*

## វិស័យកាត់ដេរសម្លៀកបំពាក់ចាប់ផ្តើមមានស្ថិរភាពឡើងវិញហើយ តើនេះមកពីកត្តាអ្វីខ្លះ ?



*ដោយ ខេមបូណ្ឌមីស*

នៅរយៈពេល ៨ខែ ក្នុងឆ្នាំ២០២១ ការនាំចេញសម្លៀក-បំពាក់ របស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិបានកើនឡើង ៣% បើប្រៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០២០។ អ្នកជំនាញក្នុងវិស័យនេះ បានមើលឃើញថា វិស័យកាត់ដេរសម្លៀកបំពាក់ នៅកម្ពុជា ចាប់ផ្តើមមានស្ថិរភាព និងមានភាពប្រសើរឡើងវិញ នារយៈពេលចុងក្រោយនេះ។

អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរកម្ពុជា បានអះអាងថា ទោះបីជាបញ្ហាកូវីដ-១៩ ជាបញ្ហាចម្បង តែវាក៏បង្កើតឱកាសសម្រាប់កម្ពុជាដែរ។ ក្នុងន័យនេះ វិបត្តិកូវីដ-១៩ បានធ្វើឱ្យប្រទេសដទៃមួយចំនួនផ្អាកដំណើរការផលិត ក្នុងផលិតកម្មសម្លៀកបំពាក់ ដោយសារការឆ្លងរាលដាលខ្លាំងនូវជំងឺកូវីដ-១៩ ដូច្នេះទីផ្សារក៏ងាកមកបញ្ជាទិញសម្លៀកបំពាក់ពីកម្ពុជាវិញ ទើបធ្វើឱ្យរយៈពេលចុងក្រោយនេះ វិស័យកាត់ដេរសម្លៀកបំពាក់ហាក់មានភាពប្រសើរឡើង។ ប្រទេសអាមេរិកជាទីផ្សារធំក្នុងចំណោមបណ្តាប្រទេសដទៃ ដែលបានបញ្ជាទិញសម្លៀកបំពាក់របស់កម្ពុជា នារយៈពេលចុងក្រោយនេះ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញថា វិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជា នារយៈពេលចុងក្រោយនេះ ហាក់មានសន្ទុះឡើងវិញ ព្រោះមានការបញ្ជាទិញជាបន្តបន្ទាប់ ដោយសារតែប្រទេសមួយចំនួន ដូចជាប្រទេសប្រេស៊ីល បង់ក្លាដេស មីយ៉ាន់ម៉ា និងវៀតណាមជាដើម គ្មានលទ្ធភាពផ្គត់ផ្គង់ទីផ្សារបាន ទើបបានធ្វើឱ្យអ្នកបញ្ជាទិញសម្រុកមកបញ្ជាទិញពីកម្ពុជាវិញ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១។*

## រដ្ឋមន្ត្រីពាណិជ្ជកម្មកម្ពុជា គ្រោងទៅប្រទេសកូរ៉េ ដើម្បីចុះហត្ថលេខា CKFTA



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១ , រូបភាព ហុង មិនា*

ឯកឧត្តម ប៉ាន សូស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម គ្រោងនឹងដឹកនាំគណៈប្រតិភូកម្ពុជាធ្វើដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូង ដើម្បីចុះហត្ថលេខាជាផ្លូវការនៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ(CKFTA)។

ប្រទេសកម្ពុជា និងកូរ៉េខាងត្បូងបានប្រកាសរួមគ្នាពីការបិទបញ្ចប់ការចរចារលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(CKFTA) តាំងពីខែកុម្ភៈ ឆ្នាំ២០២១កន្លងទៅ ដោយភាគីទាំងពីរយល់ឃើញថា កូរ៉េខាងត្បូងនឹងក្លាយជាទីផ្សារនាំចេញធំរបស់កម្ពុជា បន្ទាប់ពីប្រទេសចិន។

យោងតាមអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម លោក ប៉ែន សុវិជាតិ បានឱ្យដឹងថា ប្រសិនបើស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ នៅប្រទេសកូរ៉េខាងត្បូងមានភាពធូរស្រាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជានឹងទៅចុះហត្ថលេខាដោយផ្ទាល់នៅប្រទេសកូរ៉េ ប៉ុន្តែប្រសិនបើស្ថានភាពមិនអំណោយផលការចុះហត្ថលេខានឹងត្រូវធ្វើឡើងតាមប្រពន្ធអនឡាញវិញ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង (CKFTA) គឺជាកិច្ចខំប្រឹងប្រែង និងជោគជ័យថ្មីមួយបន្ថែមទៀតរបស់ក្រសួងពាណិជ្ជកម្មក្នុងការបើកច្រកសម្រាប់ការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។ តាមរយៈកិច្ចព្រមព្រៀង(CKFTA)នេះ ទំនិញកម្ពុជាប្រមាណជាង ១០ ០០០ បន្ទាត់ពន្ធ នឹងនាំចេញដោយរួចពន្ធទៅកូរ៉េ។ ទំនិញទាំងនោះរួមមាន៖ ទំនិញកសិផល កសិផលកែច្នៃ វាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង កាបូបធ្វើដំណើរ ផលិតផលកៅស៊ូ គ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងបន្លាស់ ផលិតផលឧស្សាហកម្មស្រាល និងផលិតផលមួយចំនួនទៀតដែលផលិតដោយអ្នកវិនិយោគក្នុង និងនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសអាចនឹងនាំចេញទៅទីផ្សារកូរ៉េ។

ស្របពេលជាមួយគ្នានេះដែរ កិច្ចព្រមព្រៀងពាណិជ្ជកម្ម(CKFTA) បានផ្តល់លក្ខណៈងាយស្រួលដល់ការនាំចូលទំនិញពីកូរ៉េខាងត្បូង មានដូចជា អេឡិចត្រូនិក ថ្នាំពេទ្យ គ្រឿងបន្លាស់រថយន្ត និងសម្ភារបរិក្ខារដែលជាវត្ថុធាតុដើម និងម៉ាស៊ីនឧបករណ៍ផលិតកម្មផ្សេងៗ សម្រាប់បម្រើឱ្យការផលិតរបស់កម្ពុជាដែលនឹងនាំឱ្យមានការកើនឡើងនូវផលិតភាពផលិតកម្ម ក៏ដូចជាគុណភាពផលិតផលសម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

ទិន្នន័យពីសមាគមពាណិជ្ជកម្មអន្តរជាតិកូរ៉េបង្ហាញថា ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ ២០២១ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-កូរ៉េ មានទឹកប្រាក់សរុបចំនួន ៤៥១,៩៨ លានដុល្លារ កើន ៦,៧២ % ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២០។ ក្នុងនោះការនាំចេញពីកម្ពុជាមានទឹកប្រាក់ ១៥៩,៤ លានដុល្លារ ធ្លាក់ចុះ ១,៦ % និងការនាំចូលពីកូរ៉េមានទឹកប្រាក់ ២៩២,៥៩ លានដុល្លារ កើន ១១,៩ %៕ ដោយ មុំ ចិន្តា

*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១]*

## រដ្ឋមន្ត្រីក្រសួងសាធារណៈការ ជំរុញការដឹកជញ្ជូនតាមផ្លូវទឹក ដើម្បីបង្កើនការនាំចេញកសិផល



*ប្រភព ៖ ខេមបូណ្ឌាមីស*

កំពង់ផែស្វយ័តភ្នំពេញ គឺជាច្រកទ្វារសេដ្ឋកិច្ចជាតិមួយដ៏សំខាន់ សម្រាប់ដោះដូរផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា ទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ។ ការដឹកជញ្ជូនទំនិញតាមផ្លូវទឹក គឺជាផ្នែកមួយយ៉ាងសំខាន់ អាចជួយកាត់បន្ថយថ្លៃដឹកជញ្ជូន។

កំពង់ផែស្វយ័តភ្នំពេញ បានចាប់ផ្តើមសាងសង់ចំណតផែកុងតឺន័រ ក្នុងជំហានទី១ ចាប់តាំងពី ឆ្នាំ២០១១មក មានសមត្ថភាពអាចផ្ទុកកុងតឺន័របាន១៥ម៉ឺន TEUs

ក្នុងមួយឆ្នាំ។ គម្រោងក្នុងដំហានទី២ មានសមត្ថភាព ផ្ទុកកុងតឺន័រ បានចំនួន៣០ម៉ឺន TEUs។ ចំណែកគម្រោងទី៣ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ មានសមត្ថភាព ផ្ទុកកុងតឺន័រ រហូតដល់៥០ម៉ឺន TEUs ក្នុងមួយឆ្នាំ។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានគូសបញ្ជាក់ថា ដើម្បីឱ្យការដឹកជញ្ជូនទំនិញតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព ត្រូវមានកិច្ចសហការគ្នា រវាងកំពង់ផែស្វយ័តភ្នំពេញ និងផែរណប៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១។*

## ដំឡូងមីរាប់ពាន់ហិកតាបានរងផលប៉ះពាល់ និងរាប់រយហិកតាបានខូចខាតដោយជំនន់ទឹកភ្លៀង



*រូបភាព ៖ ស្មើកម្ពុជា*

ដំឡូងមីរាប់ពាន់ហិកតានៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បានរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀង និងភ្លៀងធ្លាក់រណ្តំ។ ឃុំដែលរងគ្រោះជាងគេ គឺបន្ទាយឆ្មារ គោករមៀត និងគោកកបិន។

បើយោងតាមការិយាល័យកសិកម្មនៃរដ្ឋបាលស្រុក ដំឡូងមីដែលបានរងផលប៉ះពាល់ មានជាង១ ៥០០ហិកតា និងខូចខាតជិត ១ ០០០ហិកតាប៉ុណ្ណោះ ដោយសារជំនន់ទឹកភ្លៀង ហើយទឹកក៏បានស្រកចុះស្ទើរអស់ទៅហើយ។ ប៉ុន្តែមានភ្លៀងធ្លាក់មេធំៗ ដក់ទឹកជោគជាំ បណ្តាលឱ្យលិចលង់ខូចខាតជាថ្មី។ ចំពោះដំណាំផ្សេងទៀត ដូចជា ស្រូវ ដំណាំរួមផ្សំ បន្លែបង្ការ ដំណាំឆ្លងកាត់រដូវ និងជីវិតមនុស្សសត្វ មិនទាន់រងផលប៉ះពាល់នៅឡើយទេ។

ជំនន់ទឹកភ្លៀងនេះ ក៏បានបង្កការលិចលង់ផ្លូវលំជនបទជាច្រើនខ្សែផងដែរ ដូចជា ថ្មពួក ថ្មល់ដាច់ កុងសៀមណាំតៅ ធ្មេញត្រី ស្រុកភ្នំស្រុក ទៅមណ្ឌលអភិវឌ្ឍន៍អតីតយុទ្ធជនខេត្តបន្ទាយមានជ័យឬ តំបន់២២២ (ការ៉េ២) និងព្រំប្រទល់បីស្រុក(ភ្នំស្រុកស្វាយចេក និងថ្មពួក)ជាដើម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ស្មើកម្ពុជា ចេញផ្សាយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។*

## ក្រសួងពាណិជ្ជកម្មត្រៀមចាត់ការ អាជីវកម្មតាមប្រព័ន្ធអនឡាញ ដែលគ្មានអាជ្ញាបណ្ណ



*ដោយ ខេមបូណូមីស*

ក្រសួងពាណិជ្ជកម្មកម្ពុជា បានសង្កេតឃើញក្រុមហ៊ុនសហគ្រាស និងអាជីវករតាមប្រព័ន្ធអនឡាញ (Online) មួយចំនួនធំ កំពុងប្រតិបត្តិការដោយគ្មានលិខិត ឬអាជ្ញាបណ្ណអនុញ្ញាត។ ក្រសួងបានកំណត់ឱសានវាទឱ្យក្រុមហ៊ុន សហគ្រាស និងបុគ្គលរកស៊ីតាមប្រព័ន្ធអនឡាញទាំងនោះ មកដាក់ពាក្យស្នើសុំលិខិត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិកឱ្យបានមុនថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។ ក្រសួង ក៏ព្រមានពិន័យជាប្រាក់ ឬផ្អាកអាជីវកម្មណាដែលបន្តអាជីវកម្មដោយគ្មានលិខិត ឬអាជ្ញា

បណ្ណអនុញ្ញាតចាប់ពីថ្ងៃដាក់ឱសានវាទនេះ។ ពាក់ព័ន្ធនឹងតម្លៃចុះបញ្ជីនៃការស្នើសុំនេះ លិខិតអនុញ្ញាតលក្ខណៈបុគ្គលមានតម្លៃ២០ម៉ឺនរៀល លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល មានតម្លៃ៤០ម៉ឺនរៀល និងអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុនមានតម្លៃ១លានរៀល។

ជាមួយគ្នានេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានកំណត់វិធាន និងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងលើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលគ្មានគ្រឹះស្ថានអចិន្ត្រៃយ៍នៅកម្ពុជា។

អាករលើតម្លៃបន្ថែមនេះ ត្រូវបានអនុវត្តចំពោះអនិវាសនជន ឬហៅថា បុគ្គល ដែលផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីបរទេសចូលមកកម្ពុជា និងអ្នកដែលទទួលបានផលប្រយោជន៍ពីការផ្គត់ផ្គង់នេះ។ ជាមួយគ្នានេះ ក៏មានប្រតិបត្តិករOnline ហើយមិនជាប់អាករលើតម្លៃបន្ថែមនេះផងដែរ។ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០%ចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាកម្មឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

បើតាមច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្រុមហ៊ុន សហគ្រាស និងបុគ្គលរកស៊ីតាម Online ដោយគ្មានការអនុញ្ញាតនឹងរងពិន័យដោយផ្អាក ឬបិទអាជីវកម្មនិងបង់ប្រាក់រហូតដល់១០លានរៀល៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភពៈខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១*

## CDC អនុម័តគម្រោងរោងចក្រដំឡើងរថយន្តថ្មីមួយទៀត តម្លៃ៧លានដុល្លារនៅប៉ោយប៉ែត



*ប្រភព ៖ ខេមបូណ្ឌមីស*

គម្រោងរោងចក្រផ្គុំ និងដំឡើងរថយន្តថ្មីមួយទៀតហើយត្រូវបានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) អនុម័តជាផ្លូវការ ក្នុងដើមទុនចុះបញ្ជីប្រមាណ ៧លានដុល្លារអាមេរិក ដែលនឹងត្រូវសាងសង់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ភីភី ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

នៅថ្ងៃទី២១ ខែកញ្ញាឆ្នាំ២០២១ នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគ របស់ក្រុមហ៊ុន HGB MOTORS ASSEMBLY CO.,LTD. ក្នុងការបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្ត ដែលមានទីតាំងវិនិយោគស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានទុនវិនិយោគប្រមាណ ៧ លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១៦៥កន្លែង។ គេមិនទាន់ដឹងនៅឡើយទេថា ក្រុមហ៊ុនខាងលើនេះ នឹងធ្វើការដំឡើងរថយន្តម៉ាកអ្វីនៅឡើយទេ។

ក្រុមហ៊ុនមួយនេះ ត្រូវបានគេដឹងថា គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយរបស់ក្រុមហ៊ុន HGB Group របស់ឧកញ៉ា

ង៉ូវ លាងហួត ដែលជាអ្នកជំនួញដ៏លេចធ្លោមួយរូបនៅក្នុងវិស័យរថយន្តនៅកម្ពុជា។

ថ្មីៗនេះដែរ ក្រុមហ៊ុន RMA AUTOMOTIVE CO.,LTD ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ RMA Cambodia ក៏បានលាតត្រដាងពីផែនការ នឹងបោះទុនវិនិយោគប្រមាណ ២១លានដុល្លារអាមេរិក ដើម្បីសាងសង់រោងចក្រផ្គុំ និងតម្លើងរថយន្ត នៅក្នុងខេត្តពោធិ៍សាត់ផងដែរ។ បើតាមរដ្ឋបាលខេត្តពោធិ៍សាត់ គម្រោងវិនិយោគនេះនឹងអាចស្រូបយកកម្លាំងពលកម្ម ប្រមាណ ៥០០នាក់ សម្រាប់ខ្សែសង្វាក់ផលិតកម្ម និងតម្រូវការក្នុងស្រុក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០២១។*

## តើទីផ្សារចិន អាចនឹងជួយសង្គ្រោះបញ្ហានាំចេញអង្ករកម្ពុជា ដែលកំពុងដាំក្បាលចុះបានដែរ ឬយ៉ាងណា?



*ដោយ ខេមបូណ្ឌមីស*

ក្រោយជួបបញ្ហាក្នុងការនាំចេញអង្ករទៅកាន់ប្រទេសឆ្ងាយៗជាពិសេសទីផ្សារអឺរ៉ុប ដោយសារបញ្ហាកង្វះទូកុងតឺន័រ និងតម្លៃដឹកជញ្ជូនឡើងថ្លៃខ្ពស់ បច្ចុប្បន្នកម្ពុជាកំពុងយកចិត្តទុកដាក់ងាកទៅរកទីផ្សារចិន ដែលកំពុងមានតម្រូវការអង្ករប្រណីតកើនឡើង បើធៀបនឹងបណ្តាប្រទេសផ្សេងៗ។

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានបញ្ជាក់ថា កម្ពុជានឹងពង្រីកការនាំចេញអង្ករទៅកាន់ទីផ្សារចិន ដើម្បីជួយស្តារស្ថានភាពការនាំចេញអង្ករដែលបានធ្លាក់ចុះអស់រយៈពេលជាច្រើនខែកន្លងមក។ លោកបន្តថា មិនមែនមានតែកម្ពុជានោះទេ ដែលងាកទៅរកទីផ្សារចិន សូម្បីប្រទេសនាំចេញអង្ករធំៗមាន វៀតណាម ថៃ ឥណ្ឌា និងបង់ក្លាដែសជាដើម ក៏ផ្តោតខ្លាំងទៅទីផ្សារចិនដែរ ដោយសារចិនមានតម្រូវការអង្ករច្រើននៅអំឡុងនៃវិបត្តិកូវីដ-១៩ គួបផ្សំការដឹកជញ្ជូនមានភាពងាយស្រួលទាំងផ្លូវទឹក និងផ្លូវគោក។

វិបត្តិកង្វះទូកុងតឺន័រ និងតម្លៃដឹកជញ្ជូនឡើងថ្លៃ បានកើតឡើងក្រោយមានការផ្អាកដំណើរការកំពង់ផែពីប្រទេសមួយចំនួន ក្រោយពីរកឃើញមានអ្នកឆ្លងជំងឺកូវីដ-១៩ គួបផ្សំការផ្អាកការឆ្លងដែននៅតាមព្រំដែន និងជើងហោះហើរពីប្រទេសមួយទៅប្រទេសមួយ។

ប្រធានសមាគមដឹកជញ្ជូនកម្ពុជាសង្កេតឃើញ វិស័យដឹកជញ្ជូន និងឡូជីស្ទិកក្របខ័ណ្ឌក្នុងប្រទេស និងជាមួយប្រទេសជិតខាង ហាក់មានភាពល្អប្រសើរឡើងវិញបន្តិច ក្រោយរាជរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានល្អ។ ប៉ុន្តែ ការដឹកជញ្ជូនក្របខ័ណ្ឌក្រៅប្រទេសពុំទាន់មានភាពល្អប្រសើរនៅឡើយទេ ពោលគឺតម្លៃដឹកជញ្ជូនឡើងថ្លៃ និងកង្វះទូកុងតឺន័រ នៅតែជាបញ្ហាសម្រាប់វិស័យនេះ។

ទោះបីបច្ចុប្បន្ន កម្ពុជាផ្តោតខ្លាំងទៅលើទីផ្សារចិន តែកម្ពុជាមិនបោះបង់ទីផ្សារផ្សេងៗ ពិសេសអឺរ៉ុបនោះទេ ពោលគឺកម្ពុជានៅតែខិតខំស្វែងរកយុទ្ធសាស្ត្រធ្វើយ៉ាងណាបង្កើនការនាំចេញទៅកាន់ទីផ្សារទាំងនោះ។

បើតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅ៨ខែដើមឆ្នាំ២០២១ កម្ពុជាបាននាំចេញ អង្ករ ជាង៣៤ម៉ឺនតោន ធ្លាក់ចុះជាង២៣% បើធៀប នឹងរយៈពេល៨ខែកាលពីឆ្នាំ២០២០ ដែលមានជិត ៤៥ម៉ឺនតោន។ ប៉ុន្តែបើក្រឡេកទៅមើលការនាំចេញ ក្នុងខែសីហាវិញ ឃើញថា កម្ពុជាសម្រេចបានជាង ៣ម៉ឺនតោន កើនឡើងជិត៥២% បើធៀបនឹងខែសីហា កាលពីឆ្នាំមុន។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០២១។*

# តារាងប្រចាំសប្តាហ៍

## តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើមុខទំនិញនៅក្នុងខែកក្កដា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែកក្កដា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៦៩២,៩លានដុល្លារ ដែលមានកំណើនប្រមាណជា ២៩,៥% បើធៀបនឹងខែមិថុនា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់ ៣២,២លានដុល្លារនៅក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា១១,៨% បើធៀបនឹងខែមិថុនា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ ផលិតផលស្បែកសត្វ (raw furskin) គ្រឿងបន្លាស់យានយន្ត និងផលិតផលផ្សេងៗទៀត។

ស្របពេលនោះដែរ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណជា ៦៦០,៧ លានដុល្លារ នៅក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៣០,៥% បើធៀបនឹងខែមិថុនា ឆ្នាំ២០២១។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញរួមមាន៖កាបូបយួរ កាបូបដាក់លុយ សំលៀកបំពាក់ ចង្កៀងនិងគ្រឿងបំភ្លឺអគ្គីសនី និងផលិតផលផ្សេងៗទៀត។ *ដោយ មិត្ត ចន្ទី*

| **បរិយាយ** | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា |
|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** | **692.9** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% | 29.5% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 | 32.2 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% | 11.8% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 | 660.7 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% | 30.5% |

ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យពាណិជ្ជកម្មសហរដ្ឋអាមេរិក
(គិតជាលានដុល្លារ)

## តារាងទី២ ៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ប្រចាំឆមាសទី១ នៅឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាបានបង្ហាញថា៖នៅឆមាសទី១ ឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធពាណិជ្ជកម្មក្រៅប្រទេស មានចំនួនសរុប ១ ០៣២,៦៨ប៊ីលានរៀល ដែលមានការធ្លាក់ចុះបន្តិចប្រមាណជា៣,៥%បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០២០។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានចំនួនសរុប ១ ០១២,៩៥ប៊ីលានរៀល នៅក្នុងឆមាសទី១ ឆ្នាំ២០២១នេះ ដែលមានការធ្លាក់ចុះបន្តិច

ប្រមាណជា ៤,៥% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០២០។

ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញ បានចំនួន ១៩,៧៣ប៊ីលានរៀល នៅក្នុងឆមាសទី១ ឆ្នាំ២០២១ មានការកើនឡើងយ៉ាងច្រើនប្រមាណជា ១១៩,៥% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០២០៕ *ដោយៈ មិត្ត ចន្ទី*

| បរិយាយ(គិតជាប៊ីលានរៀល) | ឆមាសទី១ | | កំណើន(%) |
|---|---|---|---|
| | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| **ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស** | **1,069.89** | **1,032.68** | **-3.5%** |
| ពន្ធ និងអាករលើការនាំចូល | 1,060.90 | 1,012.95 | **-4.5%** |
| ពន្ធ និងអាករលើការនាំចេញ | 8.99 | 19.73 | **119.5%** |

*ប្រភពៈ តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែធ្នូឆ្នាំ២០២០ និងខែមិថុនាឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ចំណូលថវិការដ្ឋរបស់ប្រទេសថៃ ក្នុងរយៈពេល៧ខែដើមឆ្នាំ២០២១

រូបភាពខាងក្រោមបង្ហាញពីប្រភពចំណូលថវិការដ្ឋរបស់ប្រទេសថៃក្នុងរយៈពេល ៧ខែដើមឆ្នាំ២០២១។ ស្ថាប័នកៀរចំណូលរបស់ប្រទេសថៃត្រូវបានបែងចែកជាបីសំខាន់ៗក្នុងនោះរួមមានៈ ទី១-នាយកដ្ឋានចំណូលពន្ធរបស់រដ្ឋ(Revenue department)ដោយផ្តោតសំខាន់ទៅលើពន្ធVAT ពន្ធលើប្រាក់ចំណូលបុគ្គល ពន្ធលើប្រាក់ចំណេញ និងពន្ធលើអាជីវកម្មផ្សេងៗទៀត ទី២-នាយកដ្ឋានរដ្ឋាករ(Excise department) ទី៣-នាយកដ្ឋានពន្ធគយ (Custom department) និងប្រភពចំណូលផ្សេងៗទៀត។

គិតចាប់តាំងពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២១នេះ រដ្ឋបានប្រមូលចំណូលសរុបចំនួន ១ ៦៦៨ ៥៧៧ លានបាត ក្នុងនោះ ការប្រមូលចំណូលរបស់នាយកដ្ឋានចំណូលពន្ធរបស់រដ្ឋមានទំហំធំជាងគេមានរហូតដល់ ១ ០៩៦ ១៧៤លានបាត ពន្ធដារចំនួន ៣១១ ២៨១ លានបាត ពន្ធគយមានចំនួន ៥៩ ៦៩៩លានបាត និងចំណូលផ្សេងៗមានចំនួន ២០១ ៤២៣ លានបាត។

នៅក្នុងខែកក្កដា ការប្រមូលចំណូលរបស់នាយកដ្ឋានចំណូលពន្ធរបស់រដ្ឋមានទំហំ ១៣០ ៣១៦លានបាត ថយចុះពី ២៥៩ ២៨២ លានបាតក្នុងខែមិថុនា។ ទន្ទឹមនឹងនេះ ការប្រមូលចំណូលពន្ធរដ្ឋាករ និងពន្ធគយមិនសូវមានភាពប្រែប្រួលប៉ុន្មានទេ គឺអាចប្រមូលចំណូលបាន ៤០ ៦៧៩ លានបាត និង ៨ ៣៥៦លានបាត រៀងគ្នានៅក្នុងខែកក្កដាកន្លងទៅនេះ។ ចំណែកឯចំណូលផ្សេងៗវិញមានការកើនឡើង រហូតដល់ ៤០ ០៦២លានបាត ធៀបនឹងខែកន្លងទៅមានត្រឹមតែ ២៩ ២៦៥លានបាត៕ *ដោយ មុំ ចិន្តា*




*ប្រភពៈ Ministry of Finance Data services*

## តម្រូវការក្នុងស្រុកកូរ៉េខាងត្បូងនៅមិនច្បាស់លាស់ បើទោះជាមានសញ្ញាណនៃការងើបឡើងវិញនៃសេដ្ឋកិច្ច ស្របពេលដែលកូវីដ១៩កំពុងតែផ្ទុះឡើងវិញ



*រូបថតដោយ៖ Arirang News*

សេដ្ឋកិច្ចកូរ៉េខាងត្បូងបន្តប្រឈមមុខនឹងភាពមិនច្បាស់លាស់លើតម្រូវការក្នុងស្រុករបស់បុគ្គល សម្រាប់សេវាកម្ម នៅក្នុងពេលមានរលកទីបួននៃការរីករាលដាលនៃជំងឺកូវីដ១៩។ យោងតាមការវាយតម្លៃសេដ្ឋកិច្ចប្រចាំខែរបស់ក្រសួងហិរញ្ញវត្ថុបានបង្ហាញពីរូបភាពមិនសូវល្អមួយចំនួន បើទោះបីជាការនាំចេញមានសន្ទុះ ហើយទីផ្សារការងារមានភាពល្អប្រសើរក្តី។

នៅខែសីហា ការនាំចេញរបស់ប្រទេសកូរ៉េខាងត្បូងកើនជិត ៣៥ភាគរយ និងទីផ្សារការងារបានកើនជាង ៥០០ ពាន់កន្លែង បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ2020។ ប៉ុន្តែ ដោយមានវិធានការរក្សាគម្លាតដ៏តឹងរឹងនៅតំបន់ទីក្រុងធំៗ នាំឱ្យសន្ទស្សន៍នៃអារម្មណ៍អ្នកប្រើប្រាស់បានធ្លាក់ចុះពី ០,៧ពិន្ទុក្នុងខែសីហា មកនៅត្រឹម ១០២,៥ពិន្ទុ (point-7 points in August to 1-hundred-2.5)។

រដ្ឋាភិបាលបានសន្យាថានឹងជំរុញឱ្យសេដ្ឋកិច្ចងើបឡើងវិញ ដោយចាត់វិធានការតាមរយៈការផ្តល់មូលនិធិសង្គ្រោះកូវីដ -១៩ និងត្រួតពិនិត្យអតិផរណា៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ Arirang News ចេញផ្សាយថ្ងៃទី១៧ខែកញ្ញាឆ្នាំ២០២១*

## ការវិនិយោគបរទេសនៅវៀតណាមត្រូវបានរំពឹងថានឹងកើនឡើង ទោះជាមានបញ្ហាកូវីដ-១៩




*រូបថតដោយ៖ VNA/VNS*

ការវិនិយោគបរទេសនៅប្រទេសវៀតណាមសម្រាប់ការចាប់ផ្តើមអាជីវកម្មថ្មីៗ ត្រូវបានព្យាករថានឹងមានកើនឡើង ទោះបីជាសេដ្ឋកិច្ចវៀតណាមកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានពីកូវីដ-១៩ក្តី។ ជាក់ស្តែងធនាគារ HSBC របស់វៀតណាមបានប្រកាសគាំទ្រផ្តល់ទឹកប្រាក់ដល់ក្រុមហ៊ុន General Atlantic និងក្រុមហ៊ុន Dragoneer Investment Group ចំនួន ២៥០ លានដុល្លារអាមេរិកក្នុងការផ្តល់មូលនិធិស៊េរី B ក្នុងការសហការដឹកនាំ ក្រុមហ៊ុនផ្សារភាគហ៊ុនរួមគ្នា VNLIFE Corporation Joint Stock Company (VNLIFE) ដែលជាក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេ ក្នុងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីឌីជីថលរបស់វៀតណាម។

កាលពីដើមខែសីហាក្រុមហ៊ុន Loship ដែលជាក្រុមហ៊ុនដឹកជញ្ជូន ដែលទើបចាប់ផ្តើមនៅក្នុងប្រទេសវៀតណាមបានប្រកាសថាខ្លួនទទួលបានចំណូលចំនួន ១២ លានដុល្លារ ដែលធ្វើឱ្យតម្លៃរបស់ក្រុមហ៊ុនកើនឡើងដល់ជាង ១០០ លានដុល្លារ។ ទឹកប្រាក់នេះជួយឱ្យក្រុមហ៊ុន Loship បង្កើនវត្តមានរបស់ខ្លួននៅក្នុងទីផ្សារសំខាន់ៗចំនួន ៥ រួមមាន៖ ទីក្រុងហូជីមិញ ទីក្រុងហាណូយ ទីក្រុងណាង ទីក្រុងខានធូ និងទីក្រុងប៊ីអានហាវ។

លើសពីនោះ ដើម្បីគាំទ្រដៃគូរអាជីវកម្មដែលទើបបង្កើតថ្មី និងដើម្បីទាញយកអត្ថប្រយោជន៍ពីបរិបទនេះ ក្រុមហ៊ុន VinaCapital Group បានបង្កើតក្រុមហ៊ុន VinaCapital Ventures។ លោក Hoàng Đức Trung នាយកប្រតិបត្តិរបស់ក្រុមហ៊ុន VinaCapital Ventures បានធ្វើការកត់សម្គាល់ថា ទោះបីជានៅក្នុងអំលុងពេលមានវិបត្តិកូវីដ១៩ ក៏ដោយ ក៏ក្រុមហ៊ុនលោកនៅតែមានភាពមមាញឹកនៅក្នុងការវាយតម្លៃអាជីវកម្មដែលទើបនឹងបង្កើតថ្មីៗ និងនៅក្នុងការបញ្ចប់កិច្ចព្រមព្រៀងវិនិយោគ។

បន្ទាប់ពីកូវីដ១៩ ការចាប់ផ្ដើមអាជីវកម្មថ្មីនៅវៀតណាមត្រូវបានគេរំពឹងថា នឹងរីកចម្រើន ដោយធនាគារ HSBC របស់វៀតណាម នៅតែបន្តផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកវិនិយោគបរទេស ជាមួយក្រុមហ៊ុនវៀតណាម ដែលមានសក្ដានុពលផ្នែកបច្ចេកវិទ្យា និងបានបង្កើតយុទ្ធសាស្ត្រគាំទ្រដល់ការវិនិយោគពីបរទេសដោយផ្ទាល់ និងដោយប្រយោលថែមទៀតផង។

យោងតាមរបាយការណ៍ស្ដីពីការវិនិយោគលើការច្នៃប្រឌិត និងបច្ចេកវិទ្យារបស់វៀតណាមឆ្នាំ២០២០ ដែលចេញផ្សាយដោយមជ្ឈមណ្ឌលច្នៃប្រឌិតជាតិរបស់វៀតណាម (NIC) បានបង្ហាញថា ការវិនិយោគបច្ចេកវិទ្យារបស់វៀតណាមទទួលរងនូវផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ -១៩ ប៉ុន្តែសហគ្រិនវៀតណាមបានខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាព ដើម្បីកែប្រែបញ្ហាប្រឈមឱ្យទៅជាឱកាស។ បន្ថែមពីនោះរដ្ឋាភិបាលវៀតណាមបានខិតខំប្រឹងប្រែងជំរុញកំណើនសេដ្ឋកិច្ចឌីជីថល និងបានបង្កើតបរិយាកាសពាណិជ្ជកម្ម ដើម្បីទាក់ទាញការវិនិយោគពីបរទេស។ ដូចនេះការចាប់ផ្ដើមអាជីវកម្មថ្មីៗរបស់វៀតណាម នឹងទទួលបានឱកាសជាច្រើន ខណៈពេលដែលសកម្មភាពវិនិយោគកំពុងបន្តដំណើរការឡើងវិញ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនរបស់សិង្ហបុរី Golden Gate Ventures បានលើកឡើងថា អាជីវកម្មថ្មីៗនឹងរីកដុះដាលនៅក្នុងតំបន់ក្នុងចុងទសវត្សន៍នេះ ដែលនឹងអាចកើនឡើងលើសពី ៣០០នៅក្នុងឆ្នាំ២០៣០ ខណៈដែលប្រទេសវៀតណាមត្រូវបានគេចាត់ទុកថា ជាតារារះនៅក្នុងតំបន់៕

*ដោយ វង្ស ច័ន្ទស្មើដាក*

*ប្រភព៖ គេហទំព័រ Vietnamnews ចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០២១*

## ផ្លែស្រកានាគវៀតណាម កំពុងរងទុក្ខជាថ្មីទៀត ក្រោយចិនហាមឃាត់ការនាំចូល



*រូបភាព៖ VNA*

ប្រទេសចិន បានផ្អាកការនាំចូលផ្លែឈើមួយចំនួនពីវៀតណាម ដោយបារម្ភពីការឆ្លងកូវីដ-១៩។ ក្នុងនោះផ្លែស្រកានាគវៀតណាម ហាក់កំពុងជួបបញ្ហាខ្លាំងជាងគេ ដោយអាជ្ញាធរចិនទើបតែបានសម្រេចផ្អាកការនាំចូល ខណៈការប្រមូលផលផ្លែស្រកានាគកាន់តែកៀកខិតចូលមកដល់។ ការផ្អាកការនាំចូលនេះធ្វើឡើងក្រោយរកឃើញមេរោគកូវីដ-១៩ នៅលើកេសវេចខ្ចប់ផ្លែស្រកា

នាគ។ ផ្លែស្រកានាគ ជាផ្លែឈើពេញនិយមដាំក្នុងប្រទេសវៀតណាម ហើយប្រទេសចិនជាទីផ្សារផ្លែស្រកានាគ ស្ទើរតែ៨០%នៃការនាំចេញសរុប។

បញ្ហាមានកូវីដ-១៩ នៅលើកេសខ្ចប់ផ្លែស្រកានាគពីវៀតណាមចុងក្រោយនេះ គឺត្រូវបានរកឃើញដោយអាជ្ញាធរចិននៅតំបន់ក្វាងស៊ី ជាប់ព្រំដែនវៀតណាម ដោយត្រូវបានដឹកមកពីខេត្តគ័ងនិញ ប្រទេសវៀតណាម។ អាជ្ញាធរ ខេត្តក្វាងស៊ីប្រទេសចិន បានឱ្យដឹងថា ការផ្អាកការនាំចូលផ្លែស្រកានាគវៀតណាមនឹងបន្តរយៈពេលមួយសប្តាហ៍ទៀត ប្រសិនបើរកឃើញមេរោគកូវីដម្តងទៀតលើការវេចខ្ចប់ផ្លែស្រកានាគ ឬផលិតផលណាមួយដែលដឹកជញ្ជូនពីប្រទេសវៀតណាម។

ចិនបានផ្អាកការនាំចូលផ្លែឈើពីតំបន់ផ្សេងទៀតផងដែរនាពេលថ្មីៗនេះ រួមទាំងម្នាស់តៃវ៉ាន់ និងផ្លែធីរី ពីខេត្តជាំងស៊ូ បន្ទាប់ពីអាជ្ញាធរបានរកឃើញមេរោគនៅលើការវេចខ្ចប់ផ្លែឈើ។ ចិនបានធ្វើតេស្តយ៉ាងយកចិត្តទុកដាក់លើអាហារនាំចូលជាពិសេសសាច់ និងអាហារសមុទ្រដើម្បីរកមើលមេរោគ ទោះបីអង្គការសុខភាពពិភពលោកនិយាយថា គ្មានភស្តុតាងណាបញ្ជាក់ថាមនុស្សអាចឆ្លងវីរុសនេះ ពីអាហារ ឬការវេចខ្ចប់អាហារក៏ដោយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០២១។*

## សេដ្ឋកិច្ចសកល

### ទីផ្សារភាគហ៊ុនសកលធ្លាក់ចុះជុំវិញវិបត្តិក្រុមហ៊ុនអចលនទ្រព្យចិន (EvergrandeGroup) និងថ្លៃហ្គាសអឺរ៉ុបឡើង



*ប្រភព៖ Sky News ២០២១*

ថ្មីៗនេះ ទីផ្សារភាគហ៊ុនសកលបានធ្លាក់ចុះយ៉ាងខ្លាំងជុំវិញការព្រួយបារម្ភសេដ្ឋកិច្ច ក្នុងនោះ វិនិយោគិនបានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងទៅលើវិបត្តិដែលនឹងអាចកើតមានចំពោះវិស័យអចលនទ្រព្យចិន បន្ថែមពីលើបញ្ហាទីផ្សារផ្គត់ផ្គង់ហ្គាសនៅអឺរ៉ុប។ ការព្រួយបារម្ភលើអនាគតនៃក្រុមហ៊ុនអចលនទ្រព្យយក្សចិន ក៏ដូចជាផលប៉ះពាល់ប្រយោលទៅលើសេដ្ឋកិច្ចចិន ដែលជាសេដ្ឋកិច្ចធំទី២នៃសកលលោក បានធ្វើឱ្យទីផ្សារភាគ-ហ៊ុនអាស៊ានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងរយៈពេលត្រឹមតែមួយយប់។ រីឯ សន្ទស្សន៍ភាគហ៊ុននៅអឺរ៉ុបក៏មានការធ្លាក់ចុះ ដោយ France's Cac 40 និង Germany's Dax ខាតបង់ប្រមាណជា ២% និង Wall Street វិញ New York's Dow Jones បានធ្លាក់ចុះ ២%ដែរ។

ជាក់ស្តែង ជុំវិញបញ្ហារបស់ក្រុមហ៊ុនយក្ស Evergrande ទៅលើការជំពាក់បំណុល ដែលមានតម្លៃសរុប ៣០៥ប៊ីលានដុល្លារនេះ និយ័តករបានធ្វើការព្រមានថា ក្នុងករណីដែលបំណុលមិនអាចដោះស្រាយបាន នោះនឹងអាចបង្កឱ្យមានហានិភ័យទៅលើប្រព័ន្ធហិរញ្ញវត្ថុចិន។ ដោយឡែក ចំពោះបញ្ហាវិបត្តិតម្លៃហ្គាស នៅក្នុងអឺរ៉ុបបានដាក់សម្ពាធទៅលើអ្នកផ្គត់ផ្គង់ថាមពលធុនតូច និងផលប៉ះពាល់ប្រយោលទៅលើការផ្គត់ផ្គង់ម្ហូបអាហារ។

ទន្ទឹមនេះដែរ វិនិយោគិន ក៏មានការព្រួយបារម្ភទៅលើផលប៉ះពាល់នៃការបន្តកើនឡើងនៃករណីជំងឺកូវីដ-១៩ និងការកើនឡើងអតិផរណា។ គួរបញ្ជាក់ថា ជាមួយនឹងកំណើនសេដ្ឋកិច្ចយឺតនោះ សេដ្ឋកិច្ចនឹងអាចឈានទៅដល់ស្ថានភាព Stagflation (អតិផរណាខ្ពស់ ស្របពេលដែលសេដ្ឋកិច្ចនៅទ្រឹង)៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ Sky News ចេញផ្សាយ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១*

## ទីផ្សារតម្លៃឧស្ម័ន(ហ្គាស)ក្នុងអឺរ៉ុប បានហក់ឡើងខ្ពស់ក្នុងអត្រាកំណើន ២៥០% ដែលបណ្ដាលឱ្យមានការព្រួយបារម្ភលើការដួលរលំនៃក្រុមហ៊ុនថាមពលរបស់ចក្រភពអង់គ្លេស



*ប្រភព៖ CNBC ២០២១, រូបភាព៖ Ying Tang*

ខណៈពេលដែលប្រទេសជាច្រើនក្នុងអឺរ៉ុប ព្យាយាមរកវិធីដោះស្រាយជាមួយនឹងវិបត្តិវិស័យថាមពលដែលមិនធ្លាប់មានពីមុន ឧស្សាហកម្មថាមពលចក្រភពអង់គ្លេស អាចនឹងតម្រង់ទៅរកការរៀបចំចាត់ចែងវិស័យនេះសារឡើងវិញ។

តម្លៃលក់រាយឧស្ម័ន(ហ្គាស) បានហក់ឡើងខ្ពស់នៅគ្រប់ប្រទេសទាំងអស់ នៅក្នុងអឺរ៉ុប ជាពិសេស ចក្រភពអង់គ្លេស។ គួរបញ្ជាក់ថា កុងត្រាតម្លៃឧស្ម័ន(ហ្គាស) បានកើនឡើងប្រមាណជា ២៥០% គិតចាប់ពីខែមករាមក។

យោងតាម លោក Robert Buckley នាយកអភិវឌ្ឍទំនាក់ទំនងនៃ Cornwell Insight បានលើកឡើងថា ការកើនឡើងនៃតម្លៃឧស្ម័ន(ហ្គាស)នេះ គឺហួសពីការគ្រប់គ្រងរបស់អ្នកផ្គត់ផ្គង់។ មូលហេតុដែលនាំឱ្យមានការកើនឡើងនៃតម្លៃឧស្ម័ន(ហ្គាស) រួមមាន ការប្រកួតប្រជែងយ៉ាងខ្លាំងលើការដឹកជញ្ជូនឧស្ម័នធម្មជាតិរវាង អឺរ៉ុបនិងអាស៊ី ការផ្អាកប្រតិបត្តិការបណ្ដោះអាសន្ននៃរោងចក្រផលិតកម្មឧស្ម័នអាមេរិក និងការរឹតបន្តឹងច្បាប់ទីផ្សារលើកាបូនរបស់សហគមន៍អឺរ៉ុប និងកត្តាផ្សេងៗទៀត។ ចំណែកឯ លោក Bill Bullen ស្ថាបនិកក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីចក្រភពអង់គ្លេស Utilita Energy ព្រមានថា ការកើនឡើងខ្ពស់នៃតម្លៃលក់រាយឧស្ម័ន(ហ្គាស) នេះ នឹងអាចនាំឱ្យក្រុមហ៊ុនជាច្រើន ក្នុងវិស័យថាមពលជួបបញ្ហាសាធនភាព(មិនមានលទ្ធភាពសងបំណុល) ទន្ទឹមនេះ នឹងធ្វើឱ្យវិស័យនេះ ត្រលប់ទៅរកស្ថានភាព Oligopoly (ក្រុមហ៊ុនមួយចំនួនតូច ដែលរស់រាន និងក្ដោបអំណាចទីផ្សារ)។

ជុំវិញបញ្ហានេះ រដ្ឋាភិបាល បានចាត់វិធានការ ក្នុងការបញ្ចប់វិបត្តិនេះ ដោយរដ្ឋាភិបាលចក្រភពអង់គ្លេស បានពិចារណាទៅលើការផ្ដល់ប្រាក់កម្ចីសង្គ្រោះទៅដល់អ្នកផ្គត់ផ្គង់ថាមពល បន្ថែមពីនេះ រដ្ឋាភិបាលបានធ្វើដាក់កំណត់លើតម្លៃថាមពល ដែលការកំហិតលើតម្លៃខ្ពស់បំផុតនឹងត្រូវធ្វើការត្រួតពិនិត្យរាល់៦ខែម្ដង។ ចំណែកឯរដ្ឋាភិបាលអេស្ប៉ាញ បានចេញរាជក្រឹត្យ(Decree) លើការកំហិតតម្លៃខ្ពស់បំផុតនៃតម្លៃលក់រាយថាមពល៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៧ ខែកញ្ញា ឆ្នាំ២០២១

- ម៉ិកស៊ិក បានបង្ហាញឱនភាពពាណិជ្ជកម្ម នៅខែកក្កដាឆ្នាំ ២០២១
- តម្លៃនៃប្រាក់កម្ចីនៅប្រេស៊ីល បានកើនឡើងនៅក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី២៨ ខែកញ្ញា ឆ្នាំ២០២១

- សន្ទស្សន៍អារម្មណ៍អ្នកប្រើប្រាស់រួម(CCSI) នៅប្រទេសកូរ៉េខាងត្បូងបានថយចុះ ក្នុងខែសីហាឆ្នាំ ២០២១
- សូចនាករទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសបារាំងបានធ្លាក់ចុះ ក្នុងខែសីហាឆ្នាំ ២០២១

ថ្ងៃពុធ ទី២៩ ខែកញ្ញា ឆ្នាំ២០២១

- សកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសអាហ្សង់ទីន បានកើនឡើង នៅខែមិថុនាឆ្នាំ ២០២១
- តម្លៃទំនិញប្រើប្រាស់របស់អេស្ប៉ាញបានកើនឡើង នៅខែសីហាឆ្នាំ ២០២១ ថ្ងៃព្រហស្បតិ៍ ទី៣០ ខែកញ្ញា ឆ្នាំ២០២១
- ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសរុស្ស៊ី បានកើនឡើង ៤,៧% នៅក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនតម្លៃនាំចូលនៅប្រទេសអាឡឺម៉ង់ ១៥% ក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី០១ ខែតុលា ឆ្នាំ២០២១

- ធនាគារកណ្តាលម៉ិកស៊ិក បានសំរេចដំឡើងអត្រាការប្រាក់គោល នៅថ្ងៃទី ១២ ខែសីហា តាមការរំពឹងទុក
- កំណើន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅប្រទេសឥណ្ឌូនេស៊ី ក្នុងខែសីហាឆ្នាំ ២០២១៕